បានថតចំលងត្រឹមត្រូវតាមច្បាប់ដើម
Certified Copy/Copie Conforme
ថ្ងៃទី(On/Le) 22 ខែ(Month/Mois) Nov
ឆ្នាំ (Year/Année) 2007
ក្រឡាបញ្ជី/ Greffier CHEA Kosal



**Declassified to Public**
**27 June 2019**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**Royaume du Cambodge**
**Nation Religion Roi**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
Chambres Extraordinaires au sein des Tribunaux Cambodgiens

ORIGINAL DOCUMENT
RECEIVED ON 22. Nov. 2007
AT 14H15
BY Kosal CHEA
ACTING CASE FILE OFFICER

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**
**Office of the Co-Investigating Judges**
**Bureau des Co-juges d'instruction**
**សំណុំរឿងព្រហ្មទណ្ឌ**
**Criminal Case File /Dossier pénal**
**លេខ/No: 002/14-08-2006**
**លេខស៊ើបសួរ/Investigation/Instruction**
**លេខ/No: 002/19-09-2007-ECCC/OCIJ**

# កំណត់ហេតុនៃកិច្ចពិភាក្សាដេញដោល
# Written Record of Adversarial Hearing
# Procès-verbal de débat contradictoire

ឆ្នាំពីរពាន់ប្រាំពីរ ខែវិច្ឆិកា ថ្ងៃទី ដប់ប្រាំបួន នៅវេលាម៉ោងដប់ប្រាំមួយ និង សែសិបប្រាំនាទីគត់

យើង **យូ ប៊ុនឡេង** និង Marcel Lemonde ជាសហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញ

ដោយមានលោក ហាម ហ៊ើល និង លោក លី ច័ន្ទតុលា ជាក្រឡាបញ្ជីអមផង

បានឃើញច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤

បានឃើញវិធាន ៦៣ នៃវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញ

ដោយមានវត្តមានរបស់ អ៊ុច ចាន់ណូរ៉ា និង តាន់ប៉ាង ដាវ័ណ្ណ ជាអ្នកបកប្រែនៃអង្គជំនុំជម្រះវិសាមញ្ញដែលបានស្បថរួចហើយ។

បានចូលខ្លួននៅចំពោះមុខយើង និងបានផ្តល់ព័ត៌មានស្តីពីអត្តសញ្ញាណដូចខាងក្រោម:

ជនឈ្មោះ **ខៀវ សំផន** ហៅ **ហែម** ភេទ ប្រុស កើតនៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ ១៩៣១ នៅ ឃុំរំចេក ស្រុករំដួល ខេត្តស្វាយរៀង ប្រទេសកម្ពុជា សញ្ជាតិ ខ្មែរ

ឪពុកឈ្មោះ ខៀវ ឡុង (ស្លាប់) ម្តាយឈ្មោះ ប៉ោ គង់ (ស្លាប់)



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia National Road 4 ,Chaom Chau , Dangkao Phnom Penh PO Box 71 ,Phnom Penh Tel:+855(0)23 218914 Fax:023 218941
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Chaom CHau, Damgkao, Phnom Penh Boîte postale 71, Phnom Penh. Tel : Tel:+855(0)23 218914 Fax:023 218941

ប្រពន្ធឈ្មោះ សុ សុជាតិ (រស់) មានកូន ០៤ នាក់
មានទីលំនៅបច្ចុប្បន្ននៅភូមិកូនខ្ពង់ សង្កាត់អូរតាវៅ ខ័ណ្ឌប៉ៃលិន ក្រុងប៉ៃលិន។
ទោសពីមុន គ្មាន។

ត្រូវដាក់ឱ្យនៅក្រោមការពិនិត្យពី

- **បទល្មើសប្រឆាំងនឹងមនុស្សជាតិ** និង
- **ការរំលោភបំពានធ្ងន់ធ្ងរនៃអនុសញ្ញាទីក្រុងហ្សឺណែវចុះថ្ងៃទី ១២ សីហា ឆ្នាំ ១៩៤៩**

បទល្មើសដែលមានចែង និង ផ្តន្ទាទោសតាមមាត្រា៥ មាត្រា៦ មាត្រា២៩ (ថ្មី) និង មាត្រា៣៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤។

ច្បាប់ដើមនៃកំណត់ហេតុនេះ ត្រូវបានសរសេរជាភាសាខ្មែរ។

☒ យើង បានប្រាប់ដល់ជនត្រូវចោទថា យើង យកបញ្ហាឃុំខ្លួនជននេះជាបណ្តោះអាសន្នមកពិចារណា ហើយ យើង បានបញ្ជាក់ប្រាប់ជននេះថា សេចក្តីសម្រេចអំពីការឃុំខ្លួននេះ អាចត្រូវបានធ្វើតែបន្ទាប់ពីកិច្ចពិភាក្សាដេញដោលនេះប៉ុណ្ណោះ។

☒ យើង បានប្រាប់ដល់ជនត្រូវចោទថា កិច្ចពិភាក្សាដេញដោលនេះ ត្រូវថតជាសម្លេង និង រូបភាព។

☒ យើងបានប្រាប់ជននេះអំពីសិទ្ធិរបស់គេក្នុងការមានមេធាវីការពារ តាមការជ្រើសរើសរបស់គេ ឬ មេធាវីដែលមានចុះឈ្មោះនៅក្នុងបញ្ជីស្របតាមវិធាន ១១(២)(ឃ) នៃវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញ។
ជននេះ ប្រកាសថា:

☒ ខ្ញុំបានតែងតាំងលោក មេធាវី សាយ បូរី និង លោក Jacques Verges ដែលមានវត្តមាននៅទីនេះ ប៉ុន្តែលោកមេធាវី Jacques Verges ដោយមិនទាន់បានទទួលស្គាល់ដោយគណៈមេធាវីកម្ពុជា មានឋានៈត្រឹមតែជាជំនួយការច្បាប់របស់លោកមេធាវី សាយ បូរី តែប៉ុណ្ណោះ។

☒ លោកមេធាវី សាយ បូរី និង លោក Jacques Verges មេធាវីរបស់ជនត្រូវចោទ មានលទ្ធភាពបានពិនិត្យសំណុំរឿង និង អាចទំនាក់ទំនងដោយសេរីជាមួយនឹងកូនក្តីខ្លួន។



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia National Road 4 ,Chaom Chau , Dangkao Phnom Penh
Mail Po Box 71 ,Phnom Penh Tel:+855(0)23 218914 Fax:023 218941
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Chaom CHau, Damgkao, Phnom Penh
Boite postale 71, Phnom Penh. Tel : Tel:+855(0)23 218914 Fax:023 218941

00153230

~~[illegible]~~
E3/557

# កិច្ចពិភាក្សាដេញដោល

សហព្រះរាជអាជ្ញា ត្រូវបានតំណាងដោយ លោកយ៉េត ចរិយ៉ា និង លោក William Smith សហព្រះរាជអាជ្ញារង បានបង្ហាញការយល់ឃើញ និង សំណូមពររបស់ខ្លួនដូចខាងក្រោម:

<u>លោកសហព្រះរាជអាជ្ញារង យ៉េត ចរិយ៉ា:</u> លោក ខៀវ សំផនគឺជាមេដឹកនាំជាន់ខ្ពស់នៃកម្ពុជាប្រជាធិបតេយ្យ ដែលមានឥទ្ធិពល។ គាត់ជាប្រធានគណៈប្រធានរដ្ឋ និង ជាប្រធានការិយាល័យនយោបាយមជ្ឈិម និង ជាសមាជិកនៃគណៈកម្មាធិការមជ្ឈិមបក្ស នៅពេលដែលបក្សនេះនៅកាន់អំណាចនៅចន្លោះរវាងថ្ងៃ១៧ មេសា ១៩៧៥ និង ៦ មករា ១៩៧៩។ យើងសុំឱ្យឃុំខ្លួនគាត់ជាបណ្ដោះអាសន្ន ដោយមូលហេតុដូចខាងក្រោម:

ទី១ ដើម្បីធានាការបង្ហាញខ្លួនគាត់នៅតុលាការ ពីព្រោះ វាមានហានិភ័យនៃការរត់គេចខ្លួន ដោយសារគាត់មានទីលំនៅជិតព្រំដែនថៃ និងគាត់អាចនឹងទទួលទោសជាប់គុកមួយជីវិតផងដែរ។ ម្យ៉ាងទៀត ការដាក់ឱ្យខៀវសំផននៅមានសេរីភាព អាចបណ្ដាលឱ្យមានការខឹងសម្បាររបស់ជនរងគ្រោះ និងសាធារណជន។ ដូច្នេះ វានឹងមានហានិភ័យចំពោះសណ្ដាប់ធ្នាប់សាធារណៈ និង ការសងសឹកផ្ទាល់ខ្លួន ដែលនឹងនាំឱ្យសន្តិសុខផ្ទាល់ខ្លួនរបស់ជនត្រូវចោទ ស្ថិតនៅក្នុងសភាពគ្រោះថ្នាក់។

ចុងបញ្ចប់ សាក្សីភាគច្រើន សុទ្ធតែជាអតីតអ្នកនៅក្រោមបង្គាប់ខៀវ សំផន និង មិនប៉ានផ្ដល់សក្ខីភាពទេ ក្នុងករណីដែលគាត់មានសេរីភាព។

លោក សហព្រះរាជអាជ្ញារង **William Smith:** លោកមេធាវី Verges មិនទាន់ត្រូវបានទទួលស្គាល់នៅឡើយទេ ដូច្នេះ មិនអាចធ្វើការកត់សម្គាល់ផ្ទាល់មាត់បានទេ។ ខ្ញុំ មិនបន្ថែមការកត់សម្គាល់អ្វីផ្សេងទៀតទេ។

**លោកមេធាវី សាយបូរី:** យើងបានសិក្សាដោយប្រុងប្រយ័ត្នលើដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរជាមួយលោកខៀវ សំផន ហើយ យើង មិនបានឃើញក្នុងកថាខណ្ឌ ៩១ ដល់ ៩៧ នូវចំនុចផ្សេងៗដែលជាមូលហេតុអះអាងថាលោកខៀវសំផនបានប្រព្រឹត្តនូវអំពើទាំងឡាយដែលចោទប្រកាន់គាត់ ទោះជាដោយផ្ទាល់ ឬ ដោយប្រយោលក៏ដោយ។ សហព្រះរាជអាជ្ញា គ្រាន់តែរំលឹកឡើងវិញអំពីតួនាទីរបស់លោកខៀវសំផនប៉ុណ្ណោះ។ មានការបញ្ជាក់ក្នុងដីកានោះថាគាត់ជាប្រធាននៃមន្ទីរ៨៧០ ដែលមិនត្រឹមត្រូវនោះទេ: គាត់គ្រាន់តែជាសមាជិកសាមញ្ញ ដែលមានតួនាទីត្រឹមតែរៀបចំបញ្ជីតម្លៃទំនិញសម្រាប់សហករណ៍ប៉ុណ្ណោះ។ តាមមាត្រា ២៩ ថ្មី នៃច្បាប់ស្តីពីអង្គជំនុំជម្រះវិសាមញ្ញ តួនាទីដែលកាន់កាប់ដោយបុគ្គលម្នាក់តែមួយមុខ មិនអាចជាហេតុផលអំណះអំណាងនៃការចោទប្រកាន់នោះទេ។ ជននោះ ត្រូវតែមានអំណាចពិតប្រាកដ។ ប៉ុន្តែ មិនមានភស្តុតាងជាក់ស្តែងណាមួយ ដែល



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia National Road 4 ,Chaom Chau , Dangkao Phnom Penh
[illegible] Box 71 ,Phnom Penh Tel:+855(0)23 218914 Fax:023 218941
[illegible] extraordinaires au sein des tribunaux cambodgiens, Route nationale 4, Chaom CHau, Damgkao, Phnom Penh
[illegible]le 71, Phnom Penh. Tel : Tel:+855(0)23 218914 Fax:023 218941

បង្ហាញថាលោកខៀវសំផនមានអំណាចនោះនោះទេ។ ប្រសិនបើយើងពិនិត្យរដ្ឋធម្មនុញ្ញនៃកម្ពុជាប្រជាធិបតេយ្យ អំណាចនៃប្រធានគណៈប្រធានរដ្ឋ គឺគ្រាន់តែជាតួនាទីតំណាងប៉ុណ្ណោះ ដែលស្រដៀងគ្នានឹងតួនាទីព្រះមហាក្សត្រនាពេលបច្ចុប្បន្នដែរ: ព្រះអង្គ មានព្រះរាជតួនាទីខ្ពស់ ប៉ុន្តែ មិនមានអំណាចនោះទេ។ តាមហេតុផលទាំងនេះ ការសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា មិនមានមូលដ្ឋានច្បាប់នោះទេ។

ខ្ញុំចង់រំលឹកផងដែរអំពី គោលការណ៍ដែលមានចែងក្នុងមាត្រា ២០៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ: ជនត្រូវចោទត្រូវមានសេរីភាព ហើយការឃុំខ្លួនបណ្តោះអាសន្ន អាចធ្វើបានតែក្នុងករណីពិសេសប៉ុណ្ណោះ។ ដូចគ្នាដែរ ការសន្មតជាមុនថាគ្មានទោស ត្រូវមានប្រៀបជាងការសន្មតថាមានពិរុទ្ធភាព។ សហព្រះរាជអាជ្ញា បានលើកមូលហេតុអំណះអំណាងការឃុំខ្លួន ដោយលើកអំពីគ្រោះថ្នាក់នៃការរត់គេចខ្លួន។ ទាក់ទងនឹងលំនៅដ្ឋានដែលនៅជិតព្រំដែន លោកខៀវសំផនបានបញ្ជាក់ថា ដើម្បីសម្រួលការងាររបស់តុលាការ គាត់ត្រៀមខ្លួនរួចជាស្រេចក្នុងការប្តូរលំនៅដ្ឋាននេះមកភ្នំពេញ និងផ្តល់អាស័យដ្ឋាននេះជូនលោកចៅក្រមផងដែរ។ លោកខៀវសំផនដែលមានអាយុ ៧៧ ឆ្នាំ និងដែលមិនដែលមានគោលបំណងរត់គេចខ្លួននោះទេ ត្រៀមខ្លួនជានិច្ចទទួលយកទោសដែលនឹងត្រូវប្រកាសដាក់លើរូបគាត់ ដែលកើតចេញពីការកាត់ក្តីដែលយុត្តិធម៌ត្រឹមត្រូវ។ គាត់នឹងទទួលយកការកាត់ទោសដាក់គុកអស់មួយជីវិតក្នុងលក្ខណ្ឌដែលមានការគោរពតាមច្បាប់។ ទាក់ទងនឹងការប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ គ្រោះថ្នាក់នៃការសងសឹក និង ការគម្រាមកំហែងដល់សន្តិសុខផ្ទាល់ខ្លួនរបស់លោកខៀវ សំផន ដូចគ្នាដែរ គឺមិនមានភស្តុតាងណាមួយទេ។ តាំងតែពីឆ្នាំ ១៩៩៨ មក គឺពេលដែលគាត់ចុះចូលជាមួយរដ្ឋាភិបាល គាត់បានរស់នៅផ្ទះជាច្រើននៅប៉ៃលិន ដោយមិនមានការការពារពិសេសណាមួយទេ។ គាត់បានធ្វើដំណើរជាញឹកញាប់មកភ្នំពេញ ដើម្បីជួបកូនគាត់ដែលរស់នៅកន្លែងមួយដែលមានមនុស្សច្រើន ហើយ មិនដែលមានតម្រុយណាមួយនៃការគំរាមកំហែងសោះ។ ថ្ងៃនេះ ពេលដែលគាត់ចេញពីពេទ្យកាល់ម៉ែត យើងបានសង្កេតឃើញថាមិនមានការបញ្ចេញកាយវិការស្អប់ខ្ពើមណាមួយប្រឆាំងនឹងគាត់នោះទេ។ ដូច្នេះ ការគំរាមកំហែងដល់សណ្តាប់ធ្នាប់សាធារណៈ គឺមិនមានសោះតែម្តង។ ចុងបញ្ចប់ ទាក់ទងនឹងសាក្សី ដែលជាអតីតអ្នកក្រោមបង្គាប់របស់គាត់នោះ លោកខៀវសំផន មិនដែលមានទំនាក់ទំនងជាមួយអ្នកអតីតខ្មែរក្រហមនោះទេ។ ប្រសិនបើមានការអង្កេតត្រឹមត្រូវ ត្រូវបានធ្វើឡើងនៅប៉ៃលិន គេនឹងកត់សម្គាល់ឃើញថាលោកខៀវសំផន រស់នៅជាមួយប្រពន្ធគាត់ ដោយមិនមានអ្នកបំរើទេ ដោយសារតែគាត់ក្រ ហើយ អ្នកដែលធ្លាប់ស្គាល់គាត់ (ជាអាទិ៍លោកអភិបាល អ៊ី ឈាន) កម្រមកជួបគាត់ណាស់ ដោយសារមិនចង់មានការពាក់ព័ន្ធនឹងគាត់ និង មិនមានសាក្សីណាមួយដែលភ័យខ្លាចគាត់នោះទេ។

ជាសរុបមក ប្រសិនបើដាក់លោកខៀវសំផនឲ្យមានសេរីភាព គាត់នឹងមកបង្ហាញខ្លួននៅចំពោះមុខតុលាការ។

ចំនុចបន្ថែម ខ្ញុំសុំឲ្យគាត់និយាយខ្លួនឯង។



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១
ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia National Road 4 ,Chaom Chau , Dangkao Phnom Penh
Mail Po Box 71 ,Phnom Penh Tel:+855(0)23 218914 Fax:023 218941
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Chaom CHau, Damgkao, Phnom Penh
Boite postale 71, Phnom Penh. Tel : Tel:+855(0)23 218914 Fax:023 218941

ជនត្រូវចោទ បន្ទាប់ពីមានពេលវេលាគ្រប់គ្រាន់ចាំបាច់ដើម្បីធ្វើការការពារខ្លួន បានបង្ហាញការយល់ឃើញ និង សំណូមពររបស់ខ្លួនដូចខាងក្រោម:

ទី១ ខ្ញុំចង់បញ្ជាក់ថា សារព័ត៌មានទាំងអស់ បាននិយាយអំពីខ្ញុំថាជាអ្នកដឹកនាំដែលមានតែឈ្មោះទេ ចំណែកឯសហព្រះរាជអាជ្ញាវិញ ចាត់ទុកខ្ញុំថាជាមេដឹកនាំជាន់ខ្ពស់។ ខ្ញុំមានការភ្ញាក់ផ្អើលណាស់ចំពោះចំនុចនេះ។ ទាក់ទងនឹងការលើកឡើងអំពីការរត់គេចខ្លួន ខ្ញុំបញ្ជាក់ថាខ្ញុំរស់នៅជិតព្រំដែនតែក្នុងរយៈពេលខ្លីតែប៉ុណ្ណោះ។ ខ្ញុំមិនមានលិខិតឆ្លងដែនទេ និង មិនមានប្រាក់ដើម្បីទៅរស់នៅបរទេសនោះទេ។ ទាក់ទងនឹងទោសដែលខ្ញុំអាចទទួល ខ្ញុំមិនបារម្ភទេ ដោយសារតែខ្ញុំមិនមានប្រព្រឹត្តអំពើឧក្រិដ្ឋណាមួយនោះទេ។ ខ្ញុំមិនដែលលួចជាតិមួយសេនទេ នៅពេលដែលខ្ញុំជារដ្ឋមន្ត្រីពាណិជ្ជកម្មក្នុងរបបសម្តេច នរោត្តម សីហនុ។ ជនរួមជាតិខ្ញុំទាំងអស់ ដឹងអំពីចំនុចនេះ។ គ្មាននរណាម្នាក់ដែលគិតគូរអំពីការកសាងជាតិជាងខ្ញុំនោះទេ។ ខ្ញុំសុំឲ្យមានការអង្កេតដោយអនាគតិ ហើយ ខ្ញុំសុំឲ្យគិតផងដែរអំពីប្រវត្តិសាស្ត្រកម្ពុជា ដើម្បីឲ្យការកាត់ទោសមានភាពត្រឹមត្រូវ។ អំពីការខឹងសម្បារប្រឆាំងនឹងខ្ញុំ ខ្ញុំអាចនិយាយថា នៅពេលដែលខ្ញុំមានបញ្ហាឡើងឈាមថ្មីៗនេះ គ្រប់គ្នាបានមកផ្ទះខ្ញុំ ដើម្បីជួយខ្ញុំ ហើយមានមនុស្សជាង១៥ នាក់ បានដេកនៅផ្ទះខ្ញុំនាយប់នោះផងដែរ។

ការចោទប្រកាន់របស់សហព្រះរាជអាជ្ញា មិនមានមូលដ្ឋាននោះទេ។ ទាក់ទងនឹងមុខងាររបស់ខ្ញុំ ជាប្រធានគណៈប្រធានរដ្ឋ ខ្ញុំសុំបញ្ជាក់ថា មានសមាជិកបីរូប គឺ រូបខ្ញុំផ្ទាល់ សោ ភិម និង ញឹម រស់។ មិនមានសូម្បីតែការិយាល័យសម្រាប់ការជួបប្រជុំ ហើយ ជាឧទាហរណ៍ អំណាចដែលសោ ភិម មាន គាត់មានវាក្នុងនាមជាលេខាបក្សភូមិភាគបូព៌ា គឺ មិនមែនដោយសាឋានៈគាត់ជាអនុប្រធានទី១ នៃគណៈប្រធានរដ្ឋនោះទេ។ ដូចគ្នាដែរ ចំពោះ ញឹម រស់។ ទាក់ទងនឹងឋានៈជាសមាជិកនៃគណៈកម្មាធិការមជ្ឈិម ខ្ញុំសុំបញ្ជាក់ថា គ្រប់សេចក្តីសម្រេចសំខាន់ៗ ត្រូវបានសម្រេចដោយគណៈកម្មាធិការអចិន្ត្រៃយ៍មជ្ឈិម ដែលជាអង្គការជាន់ខ្ពស់។ ហើយបន្ទាប់មក គឺបញ្ហាទាំងនោះ ត្រូវបានពិភាក្សានៅគណៈកម្មាធិការមជ្ឈិម ដែលជាអង្គការចំណុះ។ ទាក់ទងនឹងមន្ទីរ ៨៧០ ខ្ញុំទទួលបន្ទុករៀបចំតារាងតម្លៃប៉ុណ្ណោះ។ ខ្ញុំសុំបន្ថែមថា សូម្បីតែនៅក្នុងអង្គភាពនេះ វិធានស្តីពីការសម្ងាត់គឺមានភាពតឹងរឹងបំផុត: ម្នាក់ៗ គិតតែអំពីការងាររបស់ខ្លួនតែប៉ុណ្ណោះ និង មិនដឹងអំពីការងាររបស់អ្នកដទៃនោះទេ។ ដូច្នេះ ខ្ញុំមិនដឹងអំពីអ្វីដែល ឈ្មោះនេះធ្វើនោះទេ។ ឧទាហរណ៍ អំពីការងាររបស់ប្រធានដែលត្រូវជួយគណៈកម្មាធិការអចិន្ត្រៃយ៍ ក្នុងការស៊ើបអង្កេតលើកម្មាភិបាលមួយចំនួន ខ្ញុំទើបតែបានដឹងនាពេលក្រោយនេះតែប៉ុណ្ណោះ តាមរយៈការអានរបស់ខ្ញុំ នៅពេលដែលខ្ញុំរស់នៅប៉ៃលិន។ ជាចុងបញ្ចប់ ខ្ញុំសុំបញ្ជាក់ថា បញ្ញាវន្តដូចខ្ញុំ មិនអាចបំពេញការងារនោះទេ ពីព្រោះ ខ្ញុំមិនជិតស្និទ្ធនឹងមូលដ្ឋានដូចឈ្មោះនោះទេ ពីព្រោះ ការងារនេះត្រូវការធ្វើដំណើរច្រើន ចំណែកឯខ្ញុំ ខ្ញុំធ្វើការនៅក្នុងការិយាល័យខ្ញុំតែប៉ុណ្ណោះ។



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia National Road 4 ,Chaom Chau , Dangkao Phnom Penh
Mail Po Box 71 ,Phnom Penh Tel:+855(0)23 218914 Fax:023 218941
…mbres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Chaom CHau, Damgkao, Phnom Penh
…e postale 71, Phnom Penh. Tel : Tel:+855(0)23 218914 Fax:023 218941

ចុងក្រោយ ខ្ញុំទទួលបន្ទុករក្សាទំនាក់ទំនងល្អជាមួយព្រះអង្គម្ចាស់នរោត្តម សីហនុ ដើម្បីថែរក្សាឯកភាពជាតិ ប្រឆាំងនឹងអាមេរិកាំង និង វៀតណាមដែលមានមហិច្ឆតា។ ខ្ញុំមិនមានអំណាចណាមួយទេ។ ខ្ញុំមិនមានសូម្បីតែសិទ្ធិបញ្ជាឲ្យសម្លាប់មនុស្សសូម្បីតែមួយនាក់។ ខ្ញុំមិនមានអំណាចណាមួយសោះ ក្នុងការបង្រៀននយោបាយ ឬមនោគមវិជ្ជាណាមួយ។ ដោយសារតែដើមកំណើតសង្គមរបស់ខ្ញុំ ខ្ញុំត្រូវបានគេមើលឃើញថាជាបញ្ញាជនដែលស្នេហាជាតិ និង មិនអាចក្លាយជាមេបដិវត្តបាននោះទេ។ នៅពេលដែលខ្ញុំនិយាយទៅកាន់ប៉ុល ពតថាការសម្រេចជម្លៀសប្រជាជនចេញពីភ្នំពេញ និង ទីក្រុងនានា គឺជាការភ័ន្តច្រឡំដ៏ធ្ងន់ធ្ងរ ដែលនឹងនាំឲ្យយើងនៅឯកោពីប្រជាជន និង សហគមន៍អន្តរជាតិ។ គាត់បានឆ្លើយមកខ្ញុំវិញ ដោយលើកពីប្រវត្តិ Gorky និង ឡេ នីន ដែលខ្ញុំមិនដែលដឹងសោះកាលពីមុន។ ជាសង្ខេបមក មានន័យថា ខ្ញុំមិនមាន "អ្នកនៅក្រោមបង្គាប់" នោះទេ និង មិនមានហេតុផលដែលត្រូវសង្ស័យថាអ្នកនៅក្រោមបង្គាប់ខ្ញុំមិនហ៊ានមកធ្វើសាក្សីប្រឆាំងនឹងខ្ញុំនោះទេ។ ប៉ុន្តែ នៅក្នុងស្ថានភាពបច្ចុប្បន្ន វាអាចថាមនុស្សទាំងឡាយចង់ធ្វើជាសាក្សីប្រឆាំងនឹងមេដឹកនាំខ្មែរក្រហមណាមួយ គឺដើម្បីទទួលបាននូវផលប្រយោជន៍។ នេះជាបរិយាកាស ដែលខ្ញុំមើលឃើញ។

**លោកសហព្រះរាជអាជ្ញារង យ៉េត ចរិយ៉ា:** ការិយាល័យសហព្រះរាជអាជ្ញា បានតំកល់ឯកសារជាសំអាងលើដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរនៅថ្ងៃទី១៨ តុលា ២០០៧ និង នៅថ្ងៃនេះផងដែរ។

**និទ្ទេសរបស់សហចៅក្រមស៊ើបអង្កេត:** មិនមានឯកសារណាមួយដែលសហចៅក្រមស៊ើបអង្កេតបានទទួលនៅថ្ងៃនេះនោះទេ ដូច្នេះ ការលើកឡើងនេះមិនត្រូវបានយកចិត្តទុកដាក់នោះទេ។

**លោកសហព្រះរាជអាជ្ញារង យ៉េត ចរិយ៉ា:** លោកខៀវសំផន គឺជាប្រមុខរដ្ឋ នៅក្នុងរបបមួយដែលទទួលខុសត្រូវលើជនរងគ្រោះ ១លាន៧សែននាក់។ វាជាការពិតដែលថាគាត់មិនមែនជាសមាជិកនៃគណៈកម្មាធិការអចិន្ត្រៃយ៍មជ្ឈិមបក្ស ប៉ុន្តែ មានឯកសារចំនួន ១៤ បង្ហាញថាគាត់បានចូលរួមក្នុងកិច្ចប្រជុំនោះ។ ជនត្រូវចោទម្នាក់ក្នុងចំណោមជនត្រូវចោទដទៃទៀត បាននិយាយថាលោកមានវត្តមាននៅក្នុងការសម្រេចកំទេច ជូ ជេត ហៅ ស៊ី។ គាត់មិនដែលធ្វើសេចក្តីថ្លែងការណ៍ ឬ អន្តរាគមណាមួយ ដើម្បីរារាំងបទឧក្រិដ្ឋទាំងនេះនោះទេ។ ទាក់ទងនឹងកំហឹងរបស់សាធារណជន វាជាការគ្រប់គ្រាន់ក្នុងការរំលឹកថា នាពេលចាប់ផ្តើមនីតិវិធីដំបូង មានពាក្យបណ្តឹងតែ២ឬ៣ប៉ុណ្ណោះ។ ប៉ុន្តែ បច្ចុប្បន្ន បន្ទាប់ពីមានការឃាត់ខ្លួនត្រូវបានធ្វើឡើង មានពាក្យបណ្តឹងដល់ទៅជាង៥០០ ឯណោះ។ ដូច្នេះ នៅពេលនេះ ខណៈដែលសាធារណជន ត្រូវបានជូនដំណឹងថាលោកខៀវសំផនត្រូវបានបង្ហាញខ្លួននៅចំពោះមុខ



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia National Road 4 ,Chaom Chau , Dangkao Phnom Penh
Mail Po Box 71 ,Phnom Penh Tel:+855(0)23 218914 Fax:023 218941
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Chaom CHau, Damgkao, Phnom Penh
Boite postale 71, Phnom Penh. Tel : Tel:+855(0)23 218914 Fax:023 218941

ចៅក្រមស៊ើបអង្កេត ហានិភ័យ គឺអាចកើតមានពិតប្រាកដ ប្រសិនជាទុកឲ្យគាត់មានសេរីភាព។ ផងដែរ កាលពីឆ្នាំ ១៩៨១ នាពេលដែលគាត់ត្រឡប់ចូលមកភ្នំពេញ ខៀវ សំផន បានរងគ្រោះដោយអំពើហិង្សា ហើយ គាត់ត្រូវបាន សង្គ្រោះ ដោយសារតែមានអន្តរាគមពីរដ្ឋាភិបាល។ ចុងក្រោយ ទាក់ទងនឹងហានិភ័យនៃការរត់គេចខ្លួន ខ្ញុំបានសង្កេតឃើញថា ខៀវសំផនថ្មីៗនេះ បានស្នើសុំអាជ្ញាធរទៅព្យាបាលនៅប្រទេសថៃ ប៉ុន្តែ ត្រូវបានបដិសេធ ដោយអាជ្ញាធរ។ នេះ ជាការបង្ហាញថា ទោះបីជាមិនមានលិខិតឆ្លងដែនក៏ដោយ ក៏គាត់អាចធ្វើដំណើរទៅបរទេសបាន ផងដែរ។

**ជនត្រូវចោទ:** ខ្ញុំសុំលោកសហចៅក្រមស៊ើបអង្កេតពិនិត្យដោយយកចិត្តទុកដាក់បំផុតនូវកំណត់ហេតុដែលបានលើក ឡើងនោះ ដែលបញ្ជាក់ថាខ្ញុំបានចូលរួមក្នុងកិច្ចប្រជុំដែលនាពេលនោះ មានការសម្រេចកំទេចជូ ជេតនោះ។ តើនាពេលណាដែលកំណត់ហេតុនោះ ត្រូវបានរកឃើញ ? វាមានរួចទៅហើយកាលពីមុននូវការក្លែងឯកសារ ។ វាជា ឯកសារមួយរបស់ DC-Cam ដែលមានចំណងជើងថា " មេរៀនទាំង ២៦ របស់បងខៀវសំផន " ដែលលោក Craig Etcheson ជាអ្នកទទួលខុសត្រូវបោះពុម្ពផ្សាយ។ ខ្ញុំអាចបញ្ជាក់ថា ជាការក្លែងក្លាយ ពីព្រោះ ក្នុងជួរអ្នកតស៊ូខ្មែរក្រហម មិនមាននរណាម្នាក់ស្គាល់ខ្ញុំក្រោមឈ្មោះខៀវសំផននោះទេ។ សូម្បីតែកូនស្រីរបស់ អៀង ធីរិទ្ធ ដែលបានទាក់ទងនឹងមេធាវីខ្ញុំ បាននិយាយពីខ្ញុំដោយប្រើឈ្មោះហែម។

វាជាការពិតដែលថាខ្ញុំបានចូលរួមក្នុងកិច្ចប្រជុំដែលមានការពង្រីកនៃគណៈកម្មាធិការអចិន្ត្រៃយ៍ ដែលនៅក្នុងនោះគេ ពិភាក្សាតែបញ្ហាទូទៅប៉ុណ្ណោះ ដូចជាការការពារជាតិ ការកសាងជាតិ វៀតណាម ឬ ការលាលែងរបស់នរោត្តម សីហនុ។ ខ្ញុំត្រូវតែដឹង ដើម្បីអាចជម្រាបជូនទៅអ្នកការទូត។

ទាក់ទងនឹងហេតុការណ៍ឆ្នាំ១៩៨១ដែលខ្ញុំជាជនរងគ្រោះ វាកើតឡើងនៅក្នុងបរិបទពិសេសមួយ គឺការអនុវត្ត កិច្ចព្រមព្រៀងប៉ារីស។ បញ្ហានយោបាយ បានចូលមកជ្រៀតជ្រែកនៅក្នុងរឿងនេះ មិនមែនជាការស្អប់ខ្ពើមខ្ញុំ នោះទេ។ អ្នកស្រាវជ្រាវ មានការខ្វែងគំនិតគ្នាលើបញ្ហានេះ។ ចុងក្រោយ ទាក់ទងនឹងអវត្តមាននៃការថ្លែងការរបស់ ខ្ញុំប្រឆាំងនឹងនយោបាយរបស់មេដឹកនាំខ្មែរក្រហម ខ្ញុំសុំនិយាយថា: ខ្ញុំបានជំនួសនរោត្តមសីហនុក្នុងឋានៈជាប្រមុខរដ្ឋ នៅខែមេសា ១៩៧៦។ មួយខែក្រោយមក គឺថ្ងៃ ១៤ ឧសភា ១៩៧៦ មានការដាក់ឱសានវាទពីវៀតណាម តាមរយៈការប្រើបញ្ហាព្រំដែនសមុទ្រ (កំណត់ហេតុនៃកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ត្រូវបានបោះពុម្ពទាំងស្រុង ក្នុងសៀវភៅលោក Ben Kiernan ឈ្មោះ របប ប៉ុល ពត ពីទំព័រ ១១៥ ដល់ ១១៨)។ នាពេលនោះ វៀតណាម តម្រូវឲ្យមានការសើរើបន្ទាត់ប្រេវីយ៉េ។ ចំពោះ បក្សកុម្មុយនីស្តកម្ពុជា ការឆ្លើយថាបាទ នឹងនាំឲ្យមាន ការផ្ទុះគណៈបក្សកុម្មុយនិស្ត ហើយ ប្រសិនបើឆ្លើយថាទេ គឺបង្កើតឲ្យមានជម្លោះជាអមតនៅតាមព្រំដែន។



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia National Road 4 ,Chaom Chau , Dangkao Phnom Penh
Mail Po Box 71 ,Phnom Penh Tel:+855(0)23 218914 Fax:023 218941
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Chaom CHau, Damgkao, Phnom Penh
Boite postale 71, Phnom Penh. Tel : Tel:+855(0)23 218914 Fax:023 218941

នៅក្នុងស្ថានភាពបែបនេះ ក្នុងនាមជាខ្មែរ ខ្ញុំមិនអាចបើកមាត់ ដើម្បីឲ្យមានការបែកបាក់គ្នានោះទេ។ ខ្ញុំមិនដែលធ្វើអ្វីដែលនាំឲ្យខូចប្រយោជន៍ជាតិខ្ញុំនោះទេ។

☒ យើង បានប្រាប់ដល់ជនត្រូវចោទថា តាមរយៈដីកាដែលត្រូវចេញនៅថ្ងៃនេះ យើង សម្រេចឃុំខ្លួនគេបណ្ដោះអាសន្ន និង ចេញដីកាបង្គាប់ឲ្យឃុំខ្លួន។ យើងបានប្រាប់ដោយផ្ទាល់មាត់ដល់ជននេះអំពីមូលហេតុនៃសេចក្ដីសម្រេចនេះ និង បានប្រាប់ជននេះថាសេចក្ដីសម្រេចជាលាយលក្ខណ៍អក្សរលម្អិត នឹងត្រូវប្រគល់ជូនគេនៅថ្ងៃស្អែក។

☒ ឯកសារច្បាប់ដើមនៃការថតរូបភាពនិងសម្លេង ត្រូវបានបិទស្លាកបោះត្រានៅចំពោះមុខជនត្រូវចោទនេះ និង មេធាវីរបស់ជននេះ និង ត្រូវបានចុះហត្ថលេខាដោយ យើង ក្រឡាបញ្ជី សហព្រះរាជអាជ្ញា ជនត្រូវចោទ និង មេធាវីរបស់ជននេះ។

☒ ឯកសារច្បាប់ដើមមួយច្បាប់នៃការថតរូបភាពនិងសម្លេង ត្រូវបានប្រគល់ឲ្យជនត្រូវចោទនេះ។

នៅវេលាម៉ោងម្ភៃពីរនិងសែសិបនាទី យើង បានឲ្យក្រឡាបញ្ជីអានខ្លាំងៗនូវកំណត់ហេតុពិភាក្សាដេញដោលនេះ ទៅតាមអ្វីដែលបានកត់ត្រា។

☒ អានឲ្យស្ដាប់ហើយ ជនត្រូវចោទ មិនមានជំទាស់អ្វីទេ ហើយ សុខចិត្តចុះហត្ថលេខា។

| ជនត្រូវចោទ | មេធាវីជនត្រូវចោទ | សហព្រះរាជអាជ្ញា | អ្នកបកប្រែ | ក្រឡាបញ្ជី | សហចៅក្រមស៊ើបអង្កេត |
|---|---|---|---|---|---|
| **Charged Person**<br>**Personne mise en examen** | **Lawyer of Charged Person**<br>**Avocat de la personne mise en examen** | Co-Prosecutors<br>Co-procureurs | **Interpreter**<br>**Interprète** | **Greffiers** | Co- Investigating Judges<br>Co-juges d'instruction |



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia National Road 4 ,Chaom Chau , Dangkao Phnom Penh
Mail Po Box 71 ,Phnom Penh Tel:+855(0)23 218914 Fax:023 218941
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Chaom CHau, Damgkao, Phnom Penh
Boite postale 71, Phnom Penh. Tel : Tel:+855(0)23 218914 Fax:023 218941